ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៨០/១២-អេស អេក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អេស អេក អ៊ីនធើណេសសិនណាល**

អាសយដ្ឋាន ៖ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨០៩ ២៣៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

- លោក អ៊ុក សុខឿន ប្រធានក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

- **សហជីពសេរីកម្មករនៃក្រុមហ៊ុន អេស អេក**

អាសយដ្ឋាន ៖ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៥៥២ ៤៥២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សមាជិកសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនដកអ្នកស្រី សេង ធីតា និងអ្នកស្រី សេង ស្រីអូន ជាបុគ្គលិករដ្ឋបាលចេញពីរោងចក្រ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចដកអ្នកទាំងពីររូបចេញពីរោងចក្របានឡើយ ព្រោះពួកគាត់ពុំមានកំហុសអ្វីឡើយ ។

២- សមាជិកសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនដកអ្នកស្រី នួន ស្រីម៉ៅ និងអ្នកស្រី ម៉ន សុខន ជាប្រធានក្រុមចេញពីរោងចក្រ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចដកអ្នកទាំងពីរនេះ ចេញពីរោងចក្របានឡើយ ពីព្រោះពួកគាត់ពុំមានកំហុសអ្វីឡើយ ។

៣- សមាជិកសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថមសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លាម្នាក់ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ឱ្យបានឡើយ ។

៤- សមាជិកសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃស្នាក់នៅចំនួន១០ ដុល្លារម្នាក់ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ឱ្យបានឡើយ ។

៥- សមាជិកសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ចំនួន ១០ ដុល្លារម្នាក់ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៧ ដុល្លារម្នាក់ក្នុងមួយខែ ស្របតាមប្រកាសរបស់ក្រសួងលេខ ០៤១/១១ សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ។

៦- សមាជិកសហជីពសេរីកម្មករនៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោល ឱ្យបានចំនួន ៧០ ដុល្លារ ម្នាក់ក្នុងមួយខែ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលឱ្យតាមច្បាប់ស្តីពីការងារ ។

៧- សមាជិកសហជីពសេរីកម្មករទាមទារមិនឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅពេលកម្មករឈឺមានសំបុត្រពេទ្យត្រឹមត្រូវ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះប្រាក់ឈ្នួលរក្សានៅដដែល ដោយឡែកប្រាក់រង្វាន់ធ្វើការទៀងទាត់កាត់តាមសមាមាត្រចំនួនថ្ងៃដែលកម្មករអវត្តមាន។

៨- សមាជិកសហជីពសេរីកម្មករទាមទារមិនឱ្យក្រុមហ៊ុនយកសំបុត្រពេទ្យ មុនពេលកម្មករសុំច្បាប់ឈឺ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា បើកម្មករឈឺនៅពេទ្យជិតរោងចក្រ ក្រុមហ៊ុនតម្រូវឱ្យមានសំបុត្រពេទ្យនៅថ្ងៃបន្ទាប់នៃការចូលព្យាបាល ករណីឈឺត្រូវព្យាបាលនៅស្រុក ឬខេត្តនានា ពេលត្រឡប់មកវិញត្រូវមានសំបុត្រពេទ្យបង្ហាញរដ្ឋបាល។

៩- សមាជិកសហជីពសេរីកម្មករនៅតែចោទប្រកាន់ថា ក្រុមហ៊ុនកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅពេលកម្មករសុំច្បាប់សម្រាកពិសេស និងឈប់សម្រាកបំណាច់ឆ្នាំ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា នៅពេលកម្មករសុំច្បាប់ឈប់សម្រាកពិសេស និងឈប់សម្រាកបំណាច់ឆ្នាំដោយមានច្បាប់ត្រឹមត្រូវ ក្រុមហ៊ុននឹងរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅដដែល ។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤៣២ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងជួបប្រជុំមុនសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ** ៖ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ (វេលាម៉ោង ៧ និង ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពសេរីកម្មករប្រចាំរោងចក្រ អេស អេក អ៊ិនធើណេសសិនណល ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអរនូវលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ០៩ ចំណុច លើការទាមទារចំនួន ០៩ ចំណុច។ ចំណុចមិនសះជាចំនួន ០៩ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ៤៣២ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២។

កម្មករនិយោជិតបានធ្វើកូដកម្មតាំងពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ហើយកូដករនៅតែបន្តធ្វើកូដកម្មបន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដោយមានការស្នើសុំពីនិយោជក ព្រមទាំងដើម្បីបន្តនីតិវិធីអាជ្ញាកណ្តាលឱ្យស្របបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់លេខ ០១១/១២ កបអ. ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុនអេស អេក រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវ

ត្រឡប់ចូលធ្វើការវិញ ចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ នៅវេលាម៉ោង ១២ និង ៣០ នាទី រសៀល តាមវេនរបស់ខ្លួន។

ទោះបីជាយ៉ាងនេះក៏ដោយ កម្មករនិយោជិតដែលធ្វើកូដកម្មមិនបានចូលធ្វើការតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង ៧ និង ៣០ នាទី ព្រឹក។ ភាគីនិយោជកមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែភាគីកម្មករនិយោជិតមិនបានចូលរួមតាមការអញ្ជើញទេ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់ក្រុមហ៊ុន អេស អេក សំណើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីឱ្យកម្មករនិយោជិតនៅក្រុមហ៊ុន អេស អេក ផ្អាកការធ្វើកូដកម្ម។

២- ដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ លេខ ០៨ "ឈ" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ បង្គាប់ឱ្យកម្មករនិយោជិតនីក្រុមហ៊ុន អេស អេក បញ្ឈប់ការធ្វើកូដកម្មជាបន្ទាន់។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

៣- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេស អេក លេខ ៤៣២ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អេស អេក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០១២។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញសហជីពសេរីកម្មករនៃក្រុមហ៊ុន អេស អេក មកជ្រើសរើសអាជ្ញាកណ្តាល លេខ ៤៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាល ស្នើដោយសហជីពកម្មករនិយោជិត ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៤៤៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៤៤៨ កប/អក/វក/លកអ. ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ។

**អង្គហេតុ ÷**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា *“ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ”* ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជា<u>*កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរនៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល*</u> ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតនៅបន្តធ្វើកូដកម្ម។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះចែងថា*“ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ”* ពីព្រោះភាគីនៃវិវាទការងារនេះ មិនមានសិទ្ធិធ្វើកូដកម្មក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ។

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម និងសំណុំរឿងលេខ ៣៤/០៦-ហ្គោល ហ្វេមក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះ ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុង

អំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទោះបីជាមានសេចក្តីបញ្ជាលើកទី១ និងលើកទី២ ដើម្បីឱ្យកម្មករនិយោជិតចូលធ្វើការវិញក៏ដោយ ។

លើសពីនេះ សំណុំរឿងលេខ ១១០/១១-ស៊ីម៉ាញូ និងសំណុំរឿង ៥៩/១២-វីនស៊ីងចិច ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់ មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីអាជ្ញាកណ្តាល ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗទាក់ទងនឹងប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ដែរ ។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងនីតិវិធីអាជ្ញាកណ្តាល ដោយមិនព្រមគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០១១/១២ កបអ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ដោយនៅបន្តធ្វើកូដកម្ម មិនព្រមចូលធ្វើការវិញ និងមិនចូលរួមកិច្ចប្រជុំមុនសវនាការ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ៨០/១២-អេស អេក អ៊ិនធើណេសិនណល ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: ---------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា: ---------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ---------------------------------------------

THE ARBITRATION COUNCIL